**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គ្រឹះស្ថានអង្គរ**

លេខៈ..០២៩.....គសអ.....

ថ្ងៃសុក្រ ១កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

សៀមរាប, ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២០

## សេចក្តីជូនដំណឹង

## ស្តីពី

## ការលក់បណ្ណរយៈពេលវែងចូលទស្សនារមណីយដ្ឋានអង្គរ

គ្រឹះស្ថានអង្គរមានកិត្តិយស សូមគោរពជម្រាបជូន សាធារណជន អន្តរជាតិ គ្រប់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងភ្ញៀវទេសចរបរទេសដែលស្នាក់នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់មេត្តាជ្រាបថា ដើម្បីសម្រួលដល់ជនបរទេសដែលស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការទិញបណ្ណរយៈពេលវែងចូលទស្សនារមណីយដ្ឋានអង្គរ ឱ្យមានភាពងាយស្រួល និងឆាប់រហ័ស គ្រឹះស្ថានបានធ្វើការកែសម្រួលនីតិវិធីក្នុងការទិញបណ្ណរយៈពេលវែង ដោយតម្រូវឱ្យមានតែ លិខិតឆ្លងដែនភ្ជាប់ជាមួយទិដ្ឋាការរយៈពេលវែង(ចាប់ពីបីខែឡើងទៅ) និងរូបថត៤x៦ ចំនួនមួយសន្លឹកថ្មី អាចមកទិញបណ្ណរយៈពេលវែងចូលទស្សនារមណីយដ្ឋានអង្គរនៅបញ្ជរលក់បណ្ណ ដែលមានបីប្រភេទ ដូចខាងក្រោម ÷

១- បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ រយៈពេល ០១ខែ មានតម្លៃ ១០០ដុល្លារ

២- បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ រយៈពេល ០៣ខែ មានតម្លៃ ១៥០ដុល្លារ

៣- បណ្ណចូលទស្សនារមណីយដ្ឋានអង្គរ រយៈពេល ០៦ខែ មានតម្លៃ ២០០ដុល្លារ

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន អន្តរជាតិ គ្រប់ប្រតិបត្តិករទេសចរណ៍ ព្រមទាំងភ្ញៀវទេសចរបរទេសដែលស្នាក់នៅព្រះរាជាណាចក្រកម្ពុជាទាំងអស់មេត្តាជ្រាប និងអនុវត្តដូចបានជម្រាបជូនខាងលើ។

**គ្រឹះស្ថានអង្គរ**

ព្រះរាជាណាចក្រកម្ពុជា
គ.ស.អ
គ្រឹះស្ថានអង្គរ

ផ្លូវ៦០ម៉ែត្រ ភូមិត្រាំង សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា
St 60m, Treang Village, Slor Kram Commune, Siem Reap City, Siem Reap Province, Kingdom of Cambodia
www.angkorenterprise.gov.kh

ទូរស័ព្ទលេខៈ ០១២-៦០៦-៨៥២, ០៦៩-៥៦៣-៣៤៦
Phone:855-12-606-852, 855-69-563-346
Email: angkorenterprisekh@gmail.com